ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៤ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការ និងអនុគណៈកម្មការរៀបចំបុណ្យសព សម្តេចវិបុលបញ្ញា សុខ អាន សមាជិករដ្ឋសភា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៧/២៦៧ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ ស្តីពីការប្រោសព្រះរាជទានគោរមងារ ឯកឧត្តម សុខ អាន ជា សម្តេចវិបុលបញ្ញា សុខ អាន

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

បង្កើតគណៈកម្មការ និងអនុគណៈកម្មការនានា ដើម្បីរៀបចំបុណ្យសព សម្តេចវិបុលបញ្ញា សុខ អាន សមាជិករដ្ឋសភា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានសមាសភាពដូចខាងក្រោម ៖

**ក-គណៈកម្មការរៀបចំបុណ្យសព**

១-ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ ប្រធាន

២-សម្តេចព្រះពោធិវង្ស អំ លីមហេង ព្រះសង្ឃនាយករងទី២ នៃព្រះរាជាណាចក្រកម្ពុជា អនុប្រធាន

www.pheakdeylaw.com

៣-សម្តេចព្រះឧត្តមវង្សា ម្ចួន រ៉ា លេខាធិការថេរសភា នៃព្រះរាជាណាចក្រកម្ពុជា ព្រះចៅអធិការវត្តមុនីប្រសិទ្ធិវង្ស អនុប្រធាន

៤-ឯកឧត្តម ហ៊ឹម ឆែម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា អនុប្រធាន

៥-ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ អនុប្រធាន

៦-ឯកឧត្តម ឈិន កេតនា អនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការ នៃគណៈ កម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ អនុប្រធានអចិន្ត្រៃយ៍

៧-សម្តេចព្រះមហាអរិយវង្ស សៅវ៍ ចន្ទថុល្ល ព្រះអនុគណខណ្ឌចំការមន ព្រះចៅអធិការវត្តលង្កាព្រះកុសុមារាម សមាជិក

៨-ឯកឧត្តម តឹករ៉ែត សំរេច រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៩-ឯកឧត្តម ជូ គឹមឡេង រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១០-ឯកឧត្តម ឃឹម សារិទ្ធ រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

១១-ឯកឧត្តម ថាច់ ផែន រដ្ឋលេខាធិការក្រសួងព័ត៌មាន សមាជិក

១២-ឯកឧត្តម តែ គុយស៊ាង រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

១៣-លោកជំទាវ ម៉ែន ឆដា រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល សមាជិកា

១៤-ឯកឧត្តម មួន លីមហេង អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៥-ឯកឧត្តម សេង ឡេង នាយករងខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ សមាជិក

១៦-ឯកឧត្តមនាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ សមាជិក

១៧-ឯកឧត្តមនាយឧត្តមសេនីយ៍ សៅ សុខា អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

១៨-ឯកឧត្តមនាយឧត្តមសេនីយ៍ ឥត សារ៉ាត់ អគ្គមេបញ្ជាការរង និងជានាយកទីចាត់ការហ្វឹកហ្វឺន សមាជិក

១៩-ឯកឧត្តម អ៊ិត សីលា អគ្គលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

គណៈកម្មការនេះមានភារកិច្ច ចាត់ចែងរៀបចំបុណ្យសព សម្តេចវិបុលបញ្ញា សុខ អាន សមាជិករដ្ឋសភា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឲ្យបានសមរម្យតាមទំនៀមទម្លាប់ប្រពៃណី ស័ក្តិសមទៅនឹងកិត្តិយសរបស់សព ។ សមាជិកគណៈកម្មការនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ខ-អនុគណៈកម្មការពិធីសាសនា ពិធីផ្លូវការនៅគេហដ្ឋាន និងពិធីដង្ហែសពទៅឈាបនដ្ឋាន**

១-ឯកឧត្តម ហ៊ឹម ឆែម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ប្រធាន

២-ឯកឧត្តមនាយឧត្តមសេនីយ៍ ឥត សារ៉ាត់ អគ្គមេបញ្ជាការរង និងជានាយកទីចាត់ ការហ្វឹកហ្វឺន អនុប្រធាន

៣-ឯកឧត្តម ញៀម ម៉ាលី អនុរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា អនុប្រធាន

៤-ឯកឧត្តម ម៉ាន់ ម៉ុនឡាយ អគ្គលេខាធិការរងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ អនុប្រធាន

៥-ឯកឧត្តម ទេស ហេង អគ្គលេខាធិការរងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សមាជិក



www.pheakdeylaw.com

៦-ឯកឧត្តម ហ៊ី ប៉ាទី ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ សមាជិក

៧-ឯកឧត្តម ញាណ ឡើន អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា សមាជិក

៨-ឯកឧត្តម សេខ សុមុនី អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា សមាជិក

៩-ឯកឧត្តម ហ៊ី ធីរៈ អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

១០-ឯកឧត្តម ពុំ ម៉ុនច័ន្ទរ័ត្ន ទីប្រឹក្សាអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សមាជិក

១១-លោកជំទាវ សុខ ស៊ីផន ជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ សមាជិកា

១២-ឧត្តមសេនីយ៍ត្រី សុខ គន្ធា មេបញ្ជាការកងកិត្តិយស ត្រៃទ័ព សមាជិក

១៣-ឯកឧត្តម មាន ចាន់យ៉ាដា អភិបាលរងរាជធានីភ្នំពេញ សមាជិក

អនុគណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម ៖

-រៀបចំកម្មវិធីបុណ្យ កន្លែងធ្វើបុណ្យ ពិធីគោរពវិញ្ញាណក្ខន្ធនៅគេហដ្ឋានសព

-រៀបចំពិធីដង្ហែសព

-រៀបចំក្រុមបដិសណ្ឋារកិច្ចនៃអង្គភាពត្រៃទ័ព

-ចាត់ចែងពិធីសាសនាពាក់ព័ន្ធព្រះសង្ឃ និងលោកអាចារ្យ

-រៀបចំមេរុ និងវេទិកានៅឈាបនដ្ឋាន

-រៀបចំវិយោគកថា

-ចាត់ចែងឈាបនកិច្ច

-ទទួលភារកិច្ចផ្សេងទៀត តាមការចាត់តាំងពីប្រធានគណៈកម្មការ

**គ-អនុគណៈកម្មការពិធីការ បដិសណ្ឋារកិច្ច និងព័ត៌មាន**

១-ឯកឧត្តម ណូ សម្បូរ ទីប្រឹក្សាអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ប្រធាន

២-ឯកឧត្តម ឡៀន ម៉ៅ អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

៣-ឯកឧត្តម គឹម គុណាវឌ្ឍន៍ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយក ទូរទស្សន៍ជាតិកម្ពុជា សមាជិក

៤-ឯកឧត្តម ឧន់ សារ៉ាត អគ្គនាយកវិទ្យុជាតិកម្ពុជា សមាជិក

៥-លោក ទូច សារិន ប្រធាននាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៦-លោក ពាន ចំរើន ប្រធាននាយកដ្ឋានរដ្ឋបាល គជបអ សមាជិក

៧-លោក ឡេង ម៉ុនដែន ជំនួយការអម គជបអ សមាជិក

៨-លោក គ្រឹម សត្យា អនុប្រធាននាយកដ្ឋានពិធីការ និងបដិសណ្ឋារកិច្ចគជបអ សមាជិក

៩-អាចារ្យ ជឹម ឡាទី សមាជិក

អនុគណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម ៖

-រៀបចំលិខិតជូនដំណឹងមរណភាព

-រៀបចំពិធីការទទួលគោរពវិញ្ញាណក្ខន្ធ

-រៀបចំលិខិតស្នាមរដ្ឋបាលផ្សេងៗ



www.pheakdeylaw.com

-លើកសំណើសុំមេដាយជាកិច្ចបច្ឆាមរណៈ

-រៀបចំចាត់ចែងរាល់ការផ្សព្វផ្សាយព័ត៌មាន ដែលមានការពាក់ព័ន្ធនឹងពិធីបុណ្យសព

-ទទួលភារកិច្ចផ្សេងទៀត តាមការចាត់តាំងពីប្រធានគណៈកម្មការ

**ឃ-អនុគណៈកម្មការសន្តិសុខ**

១-ឯកឧត្តមនាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ ប្រធាន

២-ឯកឧត្តម តែ គុយស៊ាង រដ្ឋលេខាធិការក្រសួងសុខាភិបាល អនុប្រធាន

៣-ឯកឧត្តមនាយឧត្តមសេនីយ៍ សៅ សុខា អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អនុប្រធាន

៤-ឯកឧត្តម ឃួង ស្រេង អភិបាលរងរាជធានីភ្នំពេញ អនុប្រធាន

៥-ឯកឧត្តមនាយឧត្តមសេនីយ៍ ជួន សុវណ្ណ អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ សមាជិក

៦-ឯកឧត្តម ឧត្តមសេនីយ៍ឯក ទូច ណារ៉ុត អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋានអង្គរក្ស សមាជិក

៧-ឯកឧត្តម ឧត្តមសេនីយ៍ឯក រ័ត្ន ស្រ៊ាង មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងជាមេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ សមាជិក

៨-លោក សុខ ពេញវុធ អភិបាលខណ្ឌដូនពេញ សមាជិក

អនុគណៈកម្មការនេះ មានភារកិច្ចរៀបចំសណ្តាប់ធ្នាប់ និងសន្តិសុខសម្រាប់កម្មវិធីបុណ្យទាំងមូល ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

**ង-អនុគណៈកម្មការផ្គត់ផ្គង់ និងហិរញ្ញវត្ថុ**

១-ឯកឧត្តម ជូ គឹមឡេង រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន

២-ឯកឧត្តម មួន លីមហេង អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

៣-ឯកឧត្តម សេង ឡៀង នាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ អនុប្រធាន

៤-ឯកឧត្តម ណែត ធឿត អគ្គលេខាធិការរង គជបអ អនុប្រធាន

៥-ឯកឧត្តម ឈុន ថុន ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៦-លោក ថុន សុធន អនុប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

អនុគណៈកម្មការនេះ មានភារកិច្ចរៀបចំនិងដោះស្រាយរាល់ការចំណាយផ្សេងៗ សម្រាប់កម្មវិធីបុណ្យសព។



www.pheakdeylaw.com

**ប្រការ២.-**

រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ ថ្ងៃទី១៥ ខែ មីនា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com